មន្ទីរពេទ្យ កាល់ម៉ែត
HOPITAL Calmette

ករុណា ការប្ដេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យកាល់ម៉ែត

## Calmette's Newsletter N° 02

ខែ មេសា ២០១៧ - មិថុនា ២០១៧

ព្រឹត្តិបត្រលេខ ២

សួស្ដីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ
ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧








**ពិធីសម្ពោធដាក់ឲ្យ ប្រើប្រាស់ ជាផ្លូវការម៉ាស៊ីន** CT **ស្កេនន័រ**
ទំនើបថ្មី និង ឧបករណ៍ វេជ្ជសាស្ត្រជាច្រើនទៀត!

**ពិគ្រោះជំងឺ**
តាមការណាត់ជួប!





**ហើមជើង**
អំឡុងពេលមានផ្ទៃពោះ ជាសញ្ញាអាសន្នរឺទេ?

រៀបចំដោយ
គណៈកម្មការទស្សនាវដ្ដីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ មេសា ២០១៧ - មិថុនា ២០១៧ ទស្សនាវដ្ដីលេខ ១

# មាតិកា

១ ពិធីសម្ពោធដាក់ឲ្យ ប្រើប្រាស់ជាផ្លូវការម៉ាស៊ីន CT ស្កេនន័រ ទំនើបថ្មី និង ឧបករណ៍វេជ្ជសាស្ត្រជាច្រើនទៀត!

២ សួស្ដីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧

៣ ហើមជើងអំឡុងពេលមានផ្ទៃពោះ ជាសញ្ញាអាសន្នរឺទេ?

៤ ការប៉ះទង្គិច ឆ្អឹងកងក ទី២ ដល់ទី៧!

៥ ពិគ្រោះជំងឺតាមការណាត់ជួប!

៦ ការឈឺនៅកដៃ ចាំបាច់ត្រូវតែព្យាបាល!

៧ ផលវិបាកនៃការសម្រាលកូនដោយវះកាត់!

៨ ជំងឺរើម អាចបណ្ដាលឲ្យស្លាប់ឬទេ?

៩ វេជ្ជសាស្ត្រទំនើប បានសង្គ្រោះជីវិតអ្នកជំងឺពីជំងឺកម្រ Guillain Barre!!!

www.facebook.com/calmette.gov.kh hospital@calmette.gov.kh www.calmette.gov.kh









# ពិធីសម្ពោធដាក់ឲ្យ ប្រើប្រាស់ជាផ្លូវការម៉ាស៊ីន CT ស្កែនន័រ

## ទំនើបថ្មី និង ឧបករណ៍វេជ្ជសាស្ត្រជាច្រើនទៀត!

ថ្ងៃច័ន្ទ ទី ០៣ ខែមេសា ឆ្នាំ២០១៧ មន្ទីរពេទ្យកាល់ម៉ែត មានសេចក្តីរំភើបយ៉ាងក្រៃលែង ដោយបានបើកទំព័រថ្មីមួយទៀត ដែលនឹងត្រូវកាត់ខ្សែបូរ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវម៉ាស៊ីន និង ឧបករណ៍វេជ្ជសាស្ត្រទំនើបជាច្រើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ដោយការរីកចម្រើនផ្នែកបច្ចេកវិទ្យាកាន់តែជឿនលឿន មន្ទីរពេទ្យកាល់ម៉ែត បានបំពាក់ម៉ាស៊ីនCTស្កែនន័រទំនើបថ្មី អមដោយបន្ទប់ប្រតិបត្តិការម៉ាស៊ីនតាមស្តង់ដារវេជ្ជសាស្ត្រសាកល។ ម៉ាស៊ីន CT ស្កែនន័រថ្មីនេះមានសមត្ថភាពខ្ពស់ក្នុងការ ស្កែនលើគ្រប់សរីរាង្គមនុស្សបានយ៉ាងរហ័ស និង រូបភាពផ្តល់កាន់តែច្បាស់ល្អ និងលំអិតជាអតិបរមា។ បន្ថែមពីលើនេះ មន្ទីរពេទ្យក៏បានបំពាក់ឧបករណ៍ វេជ្ជសាស្ត្រកម្រិតស្តង់ដារ ជាច្រើនទៀតមានជាអាទិ៍ ដូចជា៖

១) ម៉ាស៊ីនថតកាំរស្មីអ៊ិចមួយគ្រឿង ជាប្រភេទម៉ាស៊ីនឌីហ្ស៊ីថល Toshiba ដែលមាន បច្ចេកវិទ្យាបង្ហាញគុណភាពរូបភាពកម្រិត ខ្ពស់ចុងក្រោយ។

២) ម៉ាស៊ីនប្រព័ន្ធបំពង់បញ្ជូន Pneumatic ជាបច្ចេកវិទ្យាមកពីប្រទេសអាឡឺម៉ង់ ទំនើបរហ័ស អាចបញ្ជូនទឹបឈាមពីគ្រប់ផ្នែក ក្នុងមន្ទីរពេទ្យទៅមន្ទីរពិសោធន៍ លើសពីនេះ អាចបញ្ជូន លទ្ធផលមន្ទីរពិសោធន៍ ហ្វីល ឯកសារផ្សេងៗ ទៅគ្រប់ផ្នែកទូទាំង មន្ទីរពេទ្យ ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមមួយទៅបីនាទី គឺជាមធ្យោបាយជំនួយក្នុងកិច្ចការវេជ្ជសាស្ត្រ អាចកាត់បន្ថយការ ប្រើប្រាស់គិលានុបដ្ឋាកបានយ៉ាងច្រើនផង និងចំណេញពេលវេលាយ៉ាងលើសលប់ ព្រមទាំងប្រសិទ្ធភាពទាន់ពេលវេលាក្នុងការ ពិនិត្យព្យាបាលបានយ៉ាងបន្ទាន់បំផុត។

៣) ម៉ាស៊ីនវាស់មុខងារសួតពេញតួខ្លួនមនុស្ស (Body Plethysmography) ជាម៉ាស៊ីនទំនើបដែលផលិតពីសភាពអឺរ៉ុប នៃប្រទេស បែលហ្ស៊ិក ពីក្រុមហ៊ុនជំនាញសម្ភារៈវេជ្ជសាស្ត្រ សម្រាប់ជំងឺសួតបេះដូង (Medisoft Cardio-Respiratory instrumentation) សម្រាប់ធ្វើរោគវិនិច្ឆ័យលើ៖

- សមត្ថភាពវាស់ជំងឺសួតខ្សោយ (Restrictive Disease) មានជំងឺក្រិនសព្វសាច់សួត (Diffuse Lung Disease ) ជាដើម។
- មានសមត្ថភាពវាស់ជំងឺតៀតទងសួត មានដូចជា (Obstructive Disease): ហឺត (Asthma) រលាកសួត ទងសួតរ៉ាំរ៉ៃ (Chronic Obstructive Pulmonary Disease) បង្កដោយបារី ឬផ្សែងផ្សេងៗ (post smoking or biomass) និងតៀតបំពង់សំឡេង (Principal air way obstructive) ព្រមទាំងមុខងារពិសេសមួយទៀតគឺ វាយតម្លៃជាក់លាក់ពីសមត្ថភាពសួត មុនដាក់ថ្នាំសណ្តំ (Pre anesthesia evaluation)។

៤) ម៉ាស៊ីនពិនិត្យបញ្ជាក់រកប្រភេទកោសិកាមហារីក(Immuno-hystochimie) ដែលអាច៖

- ធ្វើតេស្តរក facteurs de prognostic និងជួយតម្រង់ទិសនៃការព្យាបាល ក្នុងជំងឺមហារីកសុដន់
- អាចធ្វើតេស្តរកការខូចហ្សែន HER2 ដែលនាំឲ្យកើតមហារីកសុដន់
- អាចធ្វើ sous typage របស់មហារីកកូនកណ្តុរ។

# សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ
## ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧










ពិធីសូត្រមន្តបង្សុកូលឧទ្ទិសកុសល និងសម្តែងរបាំត្រុដិ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ នាថ្ងៃសុក្រ ៧ មេសា ២០១៧ នៃមន្ត្រីរាជការបុគ្គលិកមន្ទីរពេទ្យកាល់ម៉ែត និងឧទ្ទិសពរជ័យឧត្តមមង្គលជូនដល់ប្រជាពលរដ្ឋគ្រប់រូបកុំបីខាន។



















# ការប៉ះទង្គិច

## ឆ្អឹងកងក ទី២ ដល់ទី៧!

ក) មូលហេតុនៃការប៉ះទង្គិច៖

កត្តាដែលធ្វើឲ្យមានការប៉ះទង្គិចឆ្អឹងកងកនេះមាន៖ គ្រោះថ្នាក់ក្នុងការបើកបរ ធ្លាក់ពីលើទីខ្ពស់ និងការលេងកីឡា។ល។

ខ) រោគសញ្ញា៖

នៅពេលដែលមានការប៉ះទង្គិចនៅឆ្អឹងកងក ទី២ ដល់ទី ៧ វានឹងលេចឡើងនូវរោគសញ្ញាដូចជា:

- ការឈឺកញ្ចឹងកខ្លាំង
- ស្ពឹកដៃ
- ស្ពឹកជើង
- កម្រើកដៃ និងជើងមិនរួច។

គ) ការធ្វើរោគវិនិច្ឆ័យ៖

ដើម្បីដឹងច្បាស់ពីរោគវិនិច្ឆ័យករណីនេះ ការពិនិត្យដោយផ្ទាល់ទៅលើអ្នកជំងឺតាមរយៈគ្រូពេទ្យជំនាញ អមដោយការថតស្កេនន័រ និងកាំរស្មីអ៊ិច (Rx, CTS, IRM) នឹងធ្វើឲ្យការសម្រេចចិត្តព្យាបាលរបស់ក្រុមគ្រូពេទ្យទៅលើអ្នកជំងឺ ប្រកបដោយលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់។

ឃ) ការព្យាបាល៖

ទាក់ទងទៅនឹងការព្យាបាលរួមមាន ២ ករណី:

- ទី១: ចំពោះការប្រេះ ស្រាំឆ្អឹងធម្មតា (Fracture stable) គឺតម្រូវឲ្យអ្នកជំងឺពាក់រណបក រយៈពេលយ៉ាងតិច ៣ខែ។
- ទី២: ចំពោះការបាក់ឆ្អឹងដែលខូចពីទម្រង់ដើម (Fracture instable) ការវះកាត់ដោយចាប់ដែកនៅផ្នែកខាងមុខនៃឆ្អឹងកងក ជាជម្រើសដែលល្អបំផុតក្នុងការព្យាបាល។

ប្រសិទ្ធភាពនៃការព្យាបាល អាស្រ័យលើពេលវេលាពីពេលមានគ្រោះថ្នាក់ រហូតដល់ពេលព្យាបាល និង អាស្រ័យលើកម្រិតនៃការប៉ះពាល់។

ប្រសិនបើបងប្អូនមានគ្រោះថ្នាក់ ឬការប៉ះទង្គិចទៅលើឆ្អឹងកងកនេះ សូមប្រញាប់បញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យកាល់ម៉ែត ដែលមានវេជ្ជបណ្ឌិតជំនាញ និងសម្ភារៈគ្រប់គ្រាន់ដើម្បីសង្គ្រោះជនរងគ្រោះយ៉ាងមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា។




# ពិគ្រោះជំងឺ
## តាមការណាត់ជួប!

ការណាត់ជួបទុកជាមុន ពិតជាមានសារសំខាន់ណាស់ក្នុងជីវិតរស់នៅក្នុងសង្គមបច្ចុប្បន្ន ក៏ព្រោះតែពេលវេលាកាន់តែមមាញឹកទៅៗសម្រាប់មនុស្សម្នាក់ៗ។ ដោយសារវាមានសារសំខាន់យ៉ាងនេះហើយ មន្ទីរពេទ្យកាល់ម៉ែត មានបំណងជំរុញ និងលើកទឹកចិត្តខ្ពស់ដល់អតិថិជន ដែល ប្រើប្រាស់សេវាពិគ្រោះជំងឺតាមការណាត់ជួបនេះ។

សារសំខាន់ និងផលប្រយោជន៍នៃការណាត់ជួបជាមុន៖

ក) ចំណេញពេលវេលា៖
- កាត់បន្ថយការរង់ចាំយូរ ដែលពុំសមាមាត្រនឹងចំនួនអ្នកជំងឺដ៏ច្រើនក្នុងពេលតែមួយ
- បង្កភាពងាយស្រួលដល់ទាំងអស់គ្នា (ទាំងបុគ្គលិក និងអតិថិជន) ក្នុងការបម្រើ និងការមកទទួលសេវា

ខ) អតិថិជនមានទំនុកចិត្ត និងអាចបន្តតាមដានជាមួយគ្រូពេទ្យដែលធ្លាប់បានជួបជាមួយ ឬជាមួយគ្រូពេទ្យដែលគាត់ចង់ជួប

គ) រក្សាបានរបៀបរៀបរយសម្រាប់អតិថិជន និងមន្ទីរពេទ្យ

ចំណាំ៖ ក្រុមការងារផ្នែកសម្របសម្រួល នឹងទំនាក់ទំនងរំលឹកបញ្ជាក់បន្ថែម រាល់ការណាត់ជួប ១ថ្ងៃឬ ២ថ្ងៃមុន។

ដើម្បីទទួលសេវាណាត់ជួបជាមុន និងទទួលបានព័ត៌មានកាន់តែច្បាស់អំពីសេវាផ្សេងៗនៅមន្ទីរពេទ្យ សូមទំនាក់ទំនងតាមរយៈ លេខទូរស័ព្ទ អ៊ីម៉ែល វេបសាយ ឬបណ្តាញសង្គម៖

011 41 40 65 , 077 36 17 51 , 017 86 68 47 / Email: hospital@calmette.gov.kh / Website: www.calmette.gov.kh /
Facebook: www.facebook.com/calmette.gov.kh





# ហើមជើងអំឡុងពេលមានផ្ទៃពោះ ជាសញ្ញាអាសន្នរឺទេ?






១) មូលហេតុដែលបណ្ដាលឲ្យហើមអំឡុងពេលមានផ្ទៃពោះរួមមាន:

- លើសជាតិទឹកបណ្ដាលមកពីបម្រែបម្រួលអរម៉ូនអំឡុងពេលមានផ្ទៃពោះ (ជាបាតុភូតធម្មតាដែលកើតមានអំឡុងមានផ្ទៃពោះ)។
- ការសង្កត់ទៅលើសរសៃឈាមធំៗរបស់អាងត្រគាក (pelvic veins) ដោយទម្ងន់កាន់តែធ្ងន់របស់ស្បូន ដែលធ្វើឲ្យលំហូរឈាមពីចុងជើងត្រឡប់មកបេះដូង យឺតជាងធម្មតានិងចាល់ឈាមបង្កជាការហើមជើង។ ដោយហេតុផលនេះ ការហើម ភាគច្រើនកើតមាននៅអំឡុងពេលត្រីមាសទីពនៃផ្ទៃពោះ ចំពោះស្ត្រីដែលមានទឹកភ្លោះច្រើន ឬ ពពោះកូនភ្លោះ (ជាបាតុភូតធម្មតាដែលកើតមាន អំឡុងមានផ្ទៃពោះ)។
- កង្វះជាតិអាល់ប៊ុយមីន (Albumin) ដែលអាចបណ្ដាលមកពីបាត់ជាតិសាច់តាមទឹកនោម (ជំងឺទឹកនោមប្រៃ)
- ជំងឺខ្សោយតម្រងនោម ឬ ខ្សោយបេះដូង ។ល។

២) សញ្ញាអាសន្ននៃការហើមជើងអំឡុងមានផ្ទៃពោះដែលត្រូវយកចិត្តទុកដាក់រួមមាន៖

កាលណាស្ត្រីមានផ្ទៃពោះមានហើមជើងបូករួមនិងសញ្ញាមួយចំនួនដូចជា:

- លើសសម្ពាធឈាម - បាត់ដង្ហក់ - ទឹកនោមតិច - ជើងឡើងក្រហមហើយឈឺ -ល។

៣) វិធីព្យាបាល៖

ក. បើជាការហើមមានសញ្ញាអាសន្ន គួរប្រញាប់រួសរាន់មកជួបពិគ្រោះជាមួយគ្រូពេទ្យជំនាញដើម្បីវិភាគរកមូលហេតុឲ្យបានគ្រប់ជ្រុងជ្រោយ និងដើម្បីទទួលដំបូន្មាន ឬការព្យាបាលដ៏ត្រឹមត្រូវ។

ខ. បើគ្រូពេទ្យរកឃើញថាជាការហើមដោយមូលហេតុធម្មតានៃការមានគភ៌ នោះស្ត្រីយើងគួរអនុវត្តទម្លាប់មួយចំនួនដូចខាងក្រោម:

- គេងផ្អៀងមកខាងឆ្វេងដៃ ដើម្បីកាត់បន្ថយការសង្កត់របស់ស្បូនទៅ លើសរសៃឈាមធំៗ។
- ដាក់ជើងរបស់អ្នកឲ្យបានខ្ពស់ គ្រប់ពេលដែលអាចធ្វើបានដូចជា នៅពេលធ្វើការ ឬពេលគេង ឬ តម្រង់ជើងឲ្យបានញឹកញាប់ពេលអង្គុយលេង។
- ជៀសវាងការអង្គុយគងអន្ទាក់ខ្លាយូរ។
- ឧស្សាហ៍ផ្លាស់ប្តូរឥរិយាបថ រឺដើរហាត់ប្រាណដើម្បីជួយចលនាឈាមហូរបានល្អ។
- ចូរកុំបាក់ទឹកចិត្ត ព្រោះវាអាចបាត់ទៅវិញក្រោយពេលសម្រាលបុត្ររួច

“ស្ត្រីមានផ្ទៃពោះគួរតែមកតាមដាន និងពិនិត្យសុខភាពឲ្យបានទៀងទាត់ជាប្រចាំ។ ក្នុងករណីមានការហើមនិងក្តីបារម្ភណាមួយ គួរមកជួបពិគ្រោះជាមួយគ្រូពេទ្យជំនាញសម្ភព នៃមន្ទីរពេទ្យកាល់ម៉ែត ដើម្បីទទួលបាននូវការប្រឹក្សានិងព្យាបាលបានត្រឹមត្រូវទាន់ពេលវេលា ប្រកបដោយ សុវត្ថិភាព។”




# ការឈឺនៅកដៃ ចាំបាច់ត្រូវតែព្យាបាល!




ក) មូលហេតុនៃជំងឺនេះវាធ្វើឲ្យមាន៖

- ការឈឺចាប់នៅកដៃ
- ម្រាមដៃចាប់កាន់អ្វីៗមិនបាន
- គាំងចលនាសន្លាក់
- ស្ពឹតសាច់ដុំ

លោកអ្នកគួរតែមានការចាប់ផ្តើមព្យាបាលដោយចលនាឲ្យបានឆាប់រហ័សក្នុងគោលបំណងពត់ចលនាសន្លាក់កដៃដែលគាំង បង្កើនចលនាកដៃ និង ម្រាមដៃការចាប់កាន់វត្ថុផ្សេងៗ និង ស្តារចលនាការងារប្រចាំថ្ងៃឡើងវិញ ដែលអាចបម្រើការងារបានដូចធម្មតា។

ខ) វិធីព្យាបាល៖

- ព្យាបាលដោយស្ពំសរសៃម៉ាស៊ីន Micro Thermy
- ព្យាបាលដោយម៉ាស៊ីន Ultrasound

គ) តើត្រូវធ្វើចលនាលំហាត់ដោយខ្លួនឯងយ៉ាងដូចម្តេចខ្លះ?

- ការបត់និងលា កដៃ
- ត្រឡប់បាតដៃផ្កាប់និងផ្ងារ
- ប្រអប់ដៃងាកទៅខាងមេដៃ និងទៅខាងកូនដៃ
- ទាញពន្លាតដោយបត់កដៃ
- ទាញពន្លាតដោយច្រត់កដៃ
- ចលនាបត់លាម្រាមដៃ

ការតាមដាន ការពិគ្រោះ ការពិនិត្យព្យាបាល ការស្តារចលនាប្រចាំថ្ងៃឡើងវិញ ជាមួយគ្រូពេទ្យព្យាបាលដោយចលនាជាការចាំបាច់។

ដូចនេះ នៅពេលលោកអ្នកមានបញ្ហាឈឺនៅកដៃ លោកអ្នកគួរតែអញ្ជើញទៅជួបគ្រូពេទ្យជំនាញព្យាបាលដោយចលនានៅមន្ទីរពេទ្យកាល់ម៉ែត ដើម្បីទទួលការព្យាបាល និងការណែនាំលំអិតបន្ថែមពីបញ្ហានេះ។




# ផលវិបាកនៃការសម្រាលកូនដោយវះកាត់!

ជាទូទៅ ស្ត្រីត្រូវបានលើកទឹកចិត្តឲ្យសម្រាលបុត្រតាមផ្លូវធម្មជាតិ ព្រោះផលវិបាកនៃការសម្រាលតាមធម្មជាតិ មានតិចតួចជាងការវះកាត់។ ករណីក្រុមគ្រូពេទ្យសម្រេចធ្វើការវះកាត់ លុះត្រាតែការសម្រាលតាមធម្មជាតិអាចមានគ្រោះថ្នាក់ចំពោះម្តាយនិងកូន។ ប៉ុន្តែបច្ចុប្បន្ននេះអត្រានៃការសម្រាលបុត្រដោយការវះកាត់ មានការកើនឡើងជាលំដាប់គួរឲ្យព្រួយបារម្ភ ជាពិសេសការវះកាត់ដោយគ្មានមូលហេតុត្រឹមត្រូវ។ ស្ត្រីមួយចំនួនយល់ខុសថា ការសម្រាលកូនដោយវះកាត់ មាន ភាពងាយស្រួល ដោយមិនចាំបាច់ឆ្លងកាត់ការឈឺពោះសម្រាល និងមើលរំលងផលវិបាកផ្សេងៗទៅថ្ងៃអនាគត ដែលបណ្តាលមកពីការវះកាត់នេះ។ ដូច្នេះ តើមានផលវិបានអ្វីខ្លះអំឡុង និងក្រោយពេលការវះកាត់សម្រាលកូន?

ក) ផលវិបាកអំឡុងពេលវះកាត់៖

- ផលវិបាកនៃថ្នាំសណ្តំ (Syndrome de Mendelson)
- ការបាត់បង់ឈាមច្រើនពេលវះកាត់
- ការដាច់រហែកស្បូនខ្លាំង
- របួសប្លោកនោម ឬពោះវៀន ដែលទាមទារការសម្រាកពេទ្យរយ:ពេលយូរ

ខ) ផលវិបាកក្រោយពេលវះកាត់ភ្លាមៗ ១០% ទៅ ៤២%៖

- ការបង្ករោគផ្សេងៗ មានដូចជា: ការរលាកប្លោកនោម រលាកភ្នាសក្នុងរបស់ស្បូន រលាកស្រោមពោះ ឬអាចដល់បង្ករោគក្នុងសរសៃឈាម។
- ការហូរឈាមក្រោយពេលវះកាត់ មានកកឈាមលើស្នាមរបួសស្បូនឬក្រោមរបួសស្បែក
- ភាពស្លេកស្លាំង
- ផលវិបាកស្ទះសរសៃឈាមតូចៗ ជាពិសេសសរសៃឈាមក្នុងសួតធ្វើឲ្យមានវិបត្តិផ្លូវដង្ហើម

គ) ផលវិបាកក្រោយពេលវះកាត់ នៅពេលមានផ្ទៃពោះលើកក្រោយ ស្ត្រីអាចប្រឈមនឹង៖

- ការវះកាត់យកកូនសារជាថ្មី - ការធ្លាយស្បូន - សុកពាំងមាត់ស្បូន - សុកចាក់ឫសក្នុងសាច់ស្បូន ឬចាក់ដល់ប្លោកនោម

ផលវិបាកទាំងអស់នេះមិនសូវកើតមានជាញឹកញាប់ទេ តែករណីខ្លះអាចគំរាមគំហែងដល់អាយុជីវិតស្ត្រីបាន។ ដូច្នេះរាល់ការសម្រាលទាំងអស់ស្ត្រីគួរពិភាក្សាជាមួយគ្រូពេទ្យជំនាញជាមុន ដើម្បីជ្រើសរើសការសម្រាលមួយដ៏ សមស្រប និងមានសុវត្ថិភាពទាំងម្តាយនិងកូន។ វេជ្ជបណ្ឌិតជំនាញផ្នែកសម្ភពនិងរោគស្ត្រី នៃមន្ទីរពេទ្យកាល់ម៉ែត នឹងផ្តល់ដំបូន្មានដ៏ត្រឹមត្រូវជូនលោកអ្នក ក្នុងការជ្រើសរើសវិធីសម្រាលបុត្រ។











ជំងឺរើមជាជំងឺបណ្តាលមកអំពីវីរុសឈ្មោះ វ៉ារីសេឡា ហ្សូស្ទ័រ (Varicella Zoster Virus) ដែលបង្ហាញសញ្ញាលើស្បែកជាពងទឹក មានតូច មានធំ ផ្តុំគ្នាជាកញ្ចុំឬជាផ្ទាំងៗ។ ពេលឆ្លងវីរុស វ៉ារីសេឡា ហ្សូស្ទ័រ ដំបូងវាបង្កជាជំងឺអុតស្វាយ ក្រោយពេលជាសះពីជំងឺអុតស្វាយវីរុសនេះមិនងាប់ទេ វានៅសម្ងំក្នុងប្រព័ន្ធទឹករងៃ នៅពេលណាមួយសុខភាពរបស់យើងចុះខ្សោយ (ប្រព័ន្ធភាពស៊ាំ) វីរុសនេះនឹងរើឡើងបង្កជាជំងឺរើម។









# ជំងឺរើម អាចបណ្តាលឲ្យស្លាប់ឬទេ?

ក) រោគសញ្ញា៖

នៅរយៈពេល ៤ ទៅ ៥ ថ្ងៃ មុនពេលលេចចេញជំងឺនេះ អ្នកជំងឺមានអាការៈរាងអស់កម្លាំងក្តៅខ្លួនស្ទេញៗ ស្រកៀរក្រហាយៗនៅលើស្បែក ដែលវាប្រុងនឹងលេចចេញ។ បន្ទាប់មកទើបវាចេញជាពងទឹកមានតូចមានធំផ្តុំគ្នាជាកញ្ចុំឬជាផ្ទាំងៗ។ វាអាចចេញគ្រប់ទីកន្លែង នៅលើទ្រូង លើមុខ នៅដៃ។ល។ ប៉ុន្តែវាចេញតែម្ខាង មិនដែលចេញទាំងសងខាងឬព័ទ្ធជុំទេ។ ក្រោយចេញសញ្ញាលើស្បែកពី ៧ ទៅ ១០ថ្ងៃ ពងទឹកទាំងនោះក៏សះជាអស់ បន្សល់តែស្នាមសម្លាកលើស្បែក និងការឈឺចាប់ក្រហាយលើស្បែកកន្លែងចេញ។ រោគសញ្ញាឈឺចាប់និងក្រហាយលើស្បែកនេះ អាចតិចឬខ្លាំង អ្នកខ្លះឆាប់បាត់ អ្នកខ្លះយូរអាចដល់ឆ្នាំ ទៅតាមសុខភាពបុគ្គលផ្សេងៗគ្នា។

ខ) វិធីព្យាបាល៖

អ្នកជំងឺត្រូវជួបពិគ្រោះជាមួយគ្រូពេទ្យឯកទេសដើម្បីធ្វើរោគវិនិច្ឆ័យឲ្យបានត្រឹមត្រូវ។ ត្រូវប្រើឱសថប្រភេទ Acyclovir លាប និងលេបរយៈពេល ៧ ទៅ ១០ថ្ងៃ។

សូមជម្រាបបងប្អូនប្រជាពលរដ្ឋឲ្យបានជ្រាបថា ជំងឺរើមអាចព្យាបាលជាដាច់មិនបណ្តាលឲ្យមានគ្រោះថ្នាក់ឡើយ។ លើកលែងករណីពិសេស (កម្រជួប) ជំងឺរើមកើតលើអ្នកជំងឺមានសុខភាពទ្រុឌទ្រោមខ្លាំងត្រូវសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

គ) វិធីការពារ៖

វិធីមួយចំនួនដែលយើងអាចជៀសផុតពីជំងឺរើម:

- ចំពោះអ្នកមិនទាន់កើតអុតស្វាយត្រូវចាក់ថ្នាំការពារជំងឺអុតស្វាយ
- ចំពោះអ្នកកើតអុតស្វាយរួចហើយត្រូវចាក់ថ្នាំការពារជំងឺរើម។

ឃ) ប្រការត្រូវយល់ដឹង ចំពោះអ្នកជំងឺរើម៖

- ត្រូវងូតទឹកសំអាតខ្លួនប្រាណនឹងសាប៊ូជាប្រចាំ
- ត្រូវបរិភោគអាហារបំប៉នសុខភាព មិនតមអាហារអ្វីទាំងអស់។
- មិនត្រូវស្ដោះផ្លុំ ឬយកភ្លើងមកដុតលើស្បែកអ្នកជំងឺរើមទេ។

សូមលោកអ្នកធ្វើអនាម័យខ្លួនប្រាណ និងការពារពីជំងឺអុតស្វាយនិងរើម ហើយប្រសិនបើមានករណីធ្ងន់ធ្ងរណាមួយនៃជំងឺនេះ សូមមកពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញសើស្បែកនៃមន្ទីរពេទ្យកាល់ម៉ែត ដើម្បីទទួលការប្រឹក្សា និងព្យាបាលឲ្យបានត្រឹមត្រូវ។

# វេជ្ជសាស្ត្រទំនើប

## បានសង្គ្រោះជីវិតអ្នកជំងឺពីជំងឺកម្រ Guillain Barre!!!



ត្រឹមរយៈពេលតែ៦ថ្ងៃប៉ុណ្ណោះ ពីស្ពឹកចុងជើងតិចៗរហូតដៃជើងទាំង៤ទន់ខ្សោយខ្លាំងកម្រើកលែងបាន ហើយចុងក្រោយសាច់ដុំជំនួយដង្ហើមចាប់ផ្តើមខ្សោយបន្តទៀត ដែលឈានទៅដល់ការប្រឈមនិងការដាច់ខ្យល់ភ្លាមៗ។ អាការៈជំងឺកាន់តែធ្ងន់ធ្ងរពីមួយថ្ងៃទៅមួយថ្ងៃ រួមទាំងការព្យាបាលផ្សេងៗនៅខាងក្រៅមិនបានផលអ្វី ធ្វើឲ្យក្តីបារម្ភនិងក្តីអស់សង្ឃឹមកាន់តែកើនខ្លាំងឡើងៗ។ អ្នកជំងឺចាប់ដឹងខ្លួនថាគាត់កំពុងប្រឈមនឹងការបាត់បង់ជីវិត។ តែក្តីសង្ឃឹមបានចាប់ផ្តើមមានឡើងវិញបន្ទាប់ពីត្រូវបានទទួលការពន្យល់ណែនាំឲ្យបញ្ជូនអ្នកជំងឺមកកាន់មន្ទីរពេទ្យកាល់ម៉ែត ដោយលោកគ្រូពេទ្យវ័យក្មេងម្នាក់។







ភ្លាមៗក្រោយពេលមកដល់មន្ទីរពេទ្យ អ្នកជំងឺត្រូវបានធ្វើរោគវិនិច្ឆ័យជាជំងឺ Guillain Barre កម្រិតធ្ងន់ធ្ងរ។ គាត់ត្រូវបានសង្គ្រោះដោយក្រុមវេជ្ជបណ្ឌិតជំនាញចម្រុះរួមមានផ្នែកសង្គ្រោះបន្ទាន់កម្រិតធ្ងន់ ផ្នែកប្រសាទសាស្ត្រ និងផ្នែកឯកទេសជំងឺឈាម នៃមន្ទីរពេទ្យកាល់ម៉ែត។

ជាលទ្ធផលក្រោយការសង្គ្រោះដោយការប្តូរឈាមប្លាស្មាចំនួន ៤លើក ស្ថានភាពជំងឺបានធូរស្រាលយ៉ាងច្រើន ដែលនាំដល់ការភ្ញាក់ផ្អើលដល់អ្នកជំងឺ ក្រុមគ្រួសារសាច់ញាតិ និងអ្នកជិតខាងទាំងអស់ ដោយអបអរសាទរ កោតសរសើរដល់លទ្ធផលល្អ ដែលមិនធ្លាប់នឹកស្មានដល់ថាក្រុមគ្រូពេទ្យជំនាញរបស់មន្ទីរពេទ្យអាចសង្គ្រោះអ្នកជំងឺដ៏ធ្ងន់ធ្ងរនេះឲ្យធូរសះស្បើយឡើងវិញអញ្ជឹងទាល់តែសោះ។

មួយសប្តាហ៍ក្រោយចេញពីមន្ទីរពេទ្យ អ្នកជំងឺអាចក្រោកឈរដើរបាននិងអាចប្រកបមុខរបរប្រចាំថ្ងៃជាធម្មតាឡើងវិញ។ អ្នកជំងឺនិងក្រុមគ្រួសារបានធ្វើការកោតសរសើរដល់កិច្ចសហការជាផ្លែផ្កានេះ និងវាយតម្លៃខ្ពស់ដល់សមត្ថភាពព្យាបាលរបស់ក្រុមគ្រូពេទ្យជំនាញខ្មែរយើង។ គាត់បានអំពាវនាវដល់អ្នកជំងឺដែលមានរោគសញ្ញាស្ពឹកៗស្រដៀងគ្នានេះ ឲ្យប្រញាប់រួសរាន់មកពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញផ្នែកប្រសាទសាស្ត្រ ដើម្បីអាចធ្វើរោគវិនិច្ឆ័យបានរហ័ស និងទទួលការព្យាបាលបានត្រឹមត្រូវទាន់ពេលវេលា។

វេជ្ជសាស្ត្រទំនើបបានសង្គ្រោះជីវិតអ្នកជំងឺទន់ដៃជើងទាំងបួន!!!

ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត



លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh
ហ្វេសប៊ុក: www.facebook.com/calmette.gov.kh